**សេចក្តីថ្លែងការណ៍**

*រាជធានីភ្នំពេញ ថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៦*

# នៅក្នុងឱកាសនៃទិវាគ្មានការរើសអើង ម.ស.ម.ក ចេញផ្សាយកាលប្បវត្តិនៃសាវតារ ក្រុមអ្នកស្រឡាញ់ភេទដូចគ្នា និងសូមអំពាវនាវឱ្យរាជរដ្ឋាភិបាល កម្ពុជាបង្កើតឲ្យមានច្បាប់ប្រឆាំងនឹងការរើសអើង

នៅក្នុងឱកាសនៃទិវាគ្មានការរើសអើងឆ្នាំ២០១៦ នេះ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") ចេញផ្សាយនូវកាលប្បវត្តិដែលបរិយាយលម្អិតអំពីព្រឹត្តិការណ៍សំខាន់ៗមួយចំនួនចំពោះការវិវឌ្ឍនៃចលនាសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នានៅប្រទេសកម្ពុជា និងសូមអំពាវនាវដល់រាជរដ្ឋាភិបាលកម្ពុជាបង្កើតនូវយន្តការការពារផ្នែកច្បាប់ដល់អ្នកស្រឡាញ់ភេទដូចគ្នាជាបញ្ហាអាទិភាព។

តារាងបង្ហាញអំពីកាលប្បវត្តិនៃនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័របានវិវឌ្ឍយ៉ាងខ្លាំងតាមរយៈចលនាសិទ្ធិរបស់ក្រុមអ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជាចាប់តាំងពីឆ្នាំ១៩៩៤ រហូតមកដល់បច្ចុប្បន្ន ដោយបង្ហាញនូវសេចក្តីថ្លែងគាំទ្រផ្នែកនយោបាយ ចំណាត់ការរបស់រដ្ឋាភិបាលនិងការផ្លាស់ប្តូរច្បាប់ដែលបានប៉ះពាល់ដល់ដំណើរជីវិតរបស់អ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា។ នៅប៉ុន្មានខែថ្មីៗនេះ ការគាំទ្រជាសាធារណៈនិងផ្នែកនយោបាយអំពីសមភាពរបស់ក្រុមអ្នកស្រឡាញ់ភេទដូចគ្នាបាននាំឲ្យមានសន្ទុះប្រែប្រួលយ៉ាងខ្លាំង។ នៅពេលណាដែលពលរដ្ឋកាន់តែច្រើនចាប់ផ្តើមយល់ដឹងអំពីបញ្ហានិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រ នៅពេលនោះសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជាកាន់តែបង្កើននូវទំនុកចិត្តនិងធ្វើដំណើរកាន់តែខិតទៅជិតសមភាពពិតប្រាកដ។ នៅថ្ងៃនេះយើងចូលរួមប្រារព្ធទិវាគ្មានការរើសអើងទៅលើសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា និងសូមរំលឹកថាមនុស្សទាំងអស់ដែលកើតមកគឺមានសេរីភាពនិងសមភាព ព្រមទាំងមានសិទ្ធិមនុស្សជាមូលដ្ឋានដោយរួចផុតពីការរើសអើងគ្រប់រូបភាព។ កាលប្បវត្តិនៃនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រអាចរកបានជាភាសាខ្មែរនិងភាសាអង់គ្លេស។

រដ្ឋាភិបាលនិងអង្គការសង្គមស៊ីវិល ("សង្គមស៊ីវិល") បានធ្វើដំណើររួមគ្នាប្រកបដោយភាពវិជ្ជមាននៅរយៈពេលប៉ុន្មានខែចុងក្រោយនេះក្នុងផ្នែកសិទ្ធិរបស់អ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា។ អ្នកនាំពាក្យទីស្តីការគណៈរដ្ឋមន្ត្រីលោក ផៃ ស៊ីផាន បានសម្តែងឡើងជាសាធារណៈនូវការគាំទ្ររបស់រដ្ឋាភិបាលចំពោះអ្នកស្រឡាញ់ភេទដូចគ្នា ដោយលោកបានថ្លែងថា *«សង្គមកម្ពុជាមិនរើសអើងនឹងអ្នកស្រឡាញ់ភេទដូចគ្នាទេ...*

*គ្មានច្បាប់រើសអើងប្រឆាំងនឹងពួកគេ»។* នៅក្នុងសេចក្តីថ្លែងចុងក្រោយលោក ផៃ ស៊ីផាន បានថ្លែងថា *"អ្នកស្រឡាញ់ភេទដូចគ្នាទៅធ្វើការនិងបង់ពន្ធដូចមនុស្សគ្រប់រូបផ្សេងទៀត ដូច្នេះគាត់មានសិទ្ធិចូលរួមពេញលេញនៅក្នុងសង្គម ... ប្រសិនបើដៃគូស្រឡាញ់ភេទដូចគ្នា... ចង់បានសំបុត្រអាពាហ៍ពិពាហ៍ ពួកគាត់គួរតែត្រូវស្នើសុំវា។"* លោកខៀវ កាញារីទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មាន បានចូលរួមជាវិជ្ជមានមួយជំហានបន្ថែមទៀតតាមរយៈការចូលរួមយ៉ាងសកម្មជាមួយអង្គការអនាគតយុវជនកម្ពុជាអាស៊ាន ("ខេមអាស៊ាន") ក្នុងការផ្តួចផ្តើមឱ្យមានកម្មវិធីវិទ្យុជាតិដើម្បីពិភាក្សាអំពីបញ្ហាអ្នកស្រឡាញ់ភេទដូចគ្នា។ លើសពីនេះទៀត ដោយមានការគាំទ្រពីអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ ("អង្គការយូណេស្កូ") "យុទ្ធនាការពណ៌ស្វាយ" យុទ្ធនាការនេះកំពុងកើនឡើងដោយទទួលបានប្រជាប្រិយភាពនៅតាមសាលារៀនក្នុងប្រទេសកម្ពុជា។ យុទ្ធនាការនេះមានបេសកកម្មក្នុង "ការបង្កើតលំហសុវត្ថិភាពដល់សិស្សជាអ្នកស្រឡាញ់ភេទដូចគ្នានៅទូទាំងតំបន់អាស៊ាននិងប៉ាស៊ីហ្វិក"។ ការវិវឌ្ឍជាវិជ្ជមានយ៉ាងសំខាន់មួយផ្សេងទៀត គឺ ក្រសួងអប់រំយុវជននិងកីឡាកំពុងមានកិច្ចសហការជាមួយសង្គមស៊ីវិលដើម្បីបណ្តុះបណ្តាលគ្រូបង្រៀនចំនួន ៣១០០ នាក់ នៅទូទាំងប្រទេសកម្ពុជាអំពីចំណេះដឹងផ្នែកនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រ។

ស្របពេលដែលមានការរីកចម្រើនខ្លាំងយ៉ាងពិតប្រាកដចំពោះការគាំទ្រផ្លូវការដល់សិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា ក៏នៅមានការងារជាច្រើនទៀតត្រូវតែបន្តធ្វើឱ្យបានសម្រេច ដូចជាផ្នែកច្បាប់និងសង្គម រហូតទាល់តែអ្នកស្រឡាញ់ភេទដូចគ្នាក្លាយជាពលរដ្ឋស្មើភាពគ្នានៅកម្ពុជា។ នៅពេលមានការមាក់ងាយកើតមានឡើងនៅក្នុងសង្គម ជាពិសេសក្នុងរង្វង់ក្រុមគ្រួសារ គឺជាការព្រួយបារម្ភយ៉ាងខ្លាំងចំពោះអ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា។ យោងតាមការសិក្សាស្រាវជ្រាវរបស់ ម.ស.ម.ក បង្ហាញថា តួអង្គរដ្ឋក៏មានកំហុសញឹកញាប់ផងដែរ។ របាយការណ៍ស្រាវជ្រាវរបស់ ម.ស.ម.ក ក្រោមចំណងជើង "កាសម្លុតអ្នកស្រឡាញ់ភេទដូចគ្នានៅតាមសាលារៀនក្នុងប្រទេសកម្ពុជា" បានបង្ហាញថា ៦៣ ភាគរយ នៃអ្នកឆ្លើយសំណួរបានទទួលរងការសម្លុតនៅសាលារៀនដោយសារតែពួកគេជាអ្នកស្រឡាញ់ភេទដូចគ្នា។ អ្វីដែលកាន់តែគួរឱ្យព្រួយបារម្ភ ការស្រាវជ្រាវនោះបានរកឃើញថា ការរើសអើងនេះមិនមែនកើតចេញតែពីមិត្តភក្តិរួមសាលាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងពីសំណាក់គ្រូ ហើយសូម្បីតែមន្ត្រីនគរបាលក៏បានចូលរួមក្នុងការរើសអើងនេះផងដែរ។

ស្ថិតិទាំងនេះគឺជាការបង្ហាញនូវកង្វះការយល់ដឹងដ៏រាលដាលជុំវិញបញ្ហានិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រ។ អ្នកស្រឡាញ់ភេទដូចគ្នាកម្ពុជា មិនទទួលបានការគោរពអោយបានស្មើភាពគ្នាក្នុងនាមជាពលរដ្ឋឡើយ ហើយភាគច្រើននៃអ្នកទាំងនោះកំពុងបន្តរស់នៅក្នុងជ្រុងមួយនៃសង្គម។ សិស្សជាអ្នកស្រឡាញ់ភេទដូចគ្នាម្នាក់ក្នុងចំណោម១០ នាក់ មិនបានបញ្ចប់ការសិក្សាដោយសារតែការសម្លុតផ្នត់គំនិតរើងអើង ដែលអំពើបែបនេះបន្តកើតមានពេញមួយជីវិតរបស់ពួកគេ។ ពីបុរាណកាលមក ពលរដ្ឋខ្មែររួមចំណែកយ៉ាងខ្លាំងក្នុងការរើសអើងដែលបានប្រឈមដោយអ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា។ ដោយសារការព្រួយបារម្ភអំពីកេរ្តិ៍ឈ្មោះរបស់គ្រួសារ ជាញឹកញាប់អ្នកស្រឡាញ់ភេទដូចគ្នាប្រឈមនឹងការបដិសេធពីអ្នក

ជាទីស្រឡាញ់របស់ខ្លួន និងអាចត្រូវបានបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ជាមួយភេទផ្ទុយគ្នា។ ក្នុងករណីនៃអាពាហ៍ពិពាហ៍ដោយបង្ខំ ការរំលោភសេពសន្ថវៈតែងកើតមានឡើងជាធម្មតា។

នៅក្នុងឱកាសនៃទិវាគ្មានការរើសអើងនេះ ដែលគួរមានការលើកយកគតថភាពបានគូសបញ្ជាក់ខាងលើមកពិចារណា ម.ស.ម.ក សូមស្នើឱ្យរាជរដ្ឋាភិបាលកម្ពុជាបង្កើតច្បាប់ប្រឆាំងនឹងការរើសអើងឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។ ច្បាប់នេះត្រូវតែការពារក្រុមអ្នកស្រឡាញ់ភេទដូចគ្នាពីការរើសអើងគ្រប់បែបយ៉ាងក្នុងឆាកជីវិតរបស់ពួកគេ។ បទប្បញ្ញត្តិគួរតែបញ្ចូលការគោរពឲ្យបានស្មើភាពគ្នាចំពោះសិស្ស និស្សិត និងនិយោជិតដែលជាអ្នកស្រឡាញ់ភេទដូចគ្នានៅគ្រប់កម្រិតនៃគ្រឹះស្ថានអប់រំ ព្រមទាំងគោរពឲ្យបានស្មើភាពគ្នាចំពោះអ្នកស្រឡាញ់ភេទដូចគ្នានៅកន្លែងការងារនិងក្នុងដំណើរការជ្រើសរើសបុគ្គលិក ព្រមទាំងក្នុងការផ្តល់សេវាថែទាំសុខភាព។[1] លើសពីនេះទៅទៀត ត្រូវតែចែងយ៉ាងច្បាស់ចំពោះជនណាដែលបានបំពានទៅលើច្បាប់នេះ ។

**លោក យី សេដ្ឋាណាវុទ្ធ សកម្មកជនការពារសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នាមានប្រសាសន៍ថា ៖**

*"នៅក្នុងឱកាសនៃទិវាគ្មានការរើសអើងនេះ អ្នកស្រឡាញ់ភេទដូចគ្នាត្រូវបានផ្តល់ឱកាសឱ្យលើកឡើងចំណេះដឹងជុំវិញការរើសអើងដែលពួកយើងតែងប្រឈមនៅក្នុងសង្គម។ ខ្ញុំសូមអំពាវនាវឲ្យរដ្ឋាភិបាលមេត្តាគាំទ្រដល់ពួកយើងតាមរយៈការបង្កើតច្បាប់ថ្មីដែលអាចការពារយើងពីការរើសអើង។ បច្ចុប្បន្ននេះយើងឃើញជិតមានការទទួលស្គាល់តម្លៃ និងសមភាពរបស់អ្នកស្រឡាញ់ភេទដូចគ្នាកម្ពុជាហើយ។"*

**លោក នួន ស៊ីដារ៉ា អ្នកសម្របសម្រួលគម្រោងសូជី នៃ ម.ស.ម.ក មានប្រសាសន៍ថា ៖**

*"បើទោះជាមានការវិវឌ្ឍថ្មីៗខ្លះផ្នែកសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជាក៏ដោយ ក៏ចាំបាច់ត្រូវតែបង្កើតច្បាប់ប្រឆាំងនឹងការរើសអើងដែរ ដែលស្របទៅនឹងការលើកឡើងរបស់មន្ត្រីរដ្ឋាភិបាល។ អ្នកស្រឡាញ់ភេទដូចគ្នាទទួលរងការរើសអើងជាខ្លាំងជានិច្ចកាលពីសំណាក់បុគ្គលឯកជននិងតួអង្គរដ្ឋដូចជា នគរបាលជាដើម។ ដូច្នេះហើយបច្ចុប្បន្ននេះគួរមានចំណាត់ការចំពោះរឿងនេះ។"*

សិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នាគឺជាសិទ្ធិមនុស្ស ហើយបុគ្គលគ្រប់រូបត្រូវតែទទួលបានការការពារសុវត្ថិភាពប្រឆាំងនឹងការមាក់ងាយ ការយាយី និងការរើសអើងផ្អែកទៅលើនិន្នាការភេទរបស់ពួកគេ៕

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងលោក នួន ស៊ីដារ៉ា មន្ត្រីសម្របសម្រួលគម្រោងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រតាមរយៈទូរសព្ទ ៖ + ៨៥៥ (០) ៩៧ ៩៦៦៦ ៥៦៦ ឬ អ៊ីម៉ែល ៖ sidara.nuon@cchrcambodia.org ឬលោក ផាត់ ដឺ ប្រ៊ុន តាមរយៈទូរសព្ទ ៖ +៨៥៥ (០)៨៩ ៥៣៦ ២១៥ ឬអ៊ីម៉ែល ៖ pat.debrun@cchrcambodia.org។**

----

[1] អនុសាសន៍លម្អិតបន្ថែមផ្សេងទៀតដើម្បីជូនដល់ភាគីដែលពាក់ព័ន្ធ អាចរកបាននៅក្នុងរបាយការណ៍ ការសម្លុតអ្នកស្រឡាញ់ភេទដូចគ្នានៅតាមសាលារៀនក្នុងប្រទេសកម្ពុជា របស់ ម.ស.ម.ក ដែលចេញផ្សាយក្នុងខែធ្នូ ឆ្នាំ ២០១៥ < http://bit.ly/1p71s4t >

**បណ្ណាធិការ ៖**

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) បង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០០២ ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ និងមិនចូលបក្សសម្ព័ន្ធ ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយនៅកម្ពុជា។

ម.ស.ម.ក ជាសមាជិកនៃអង្គការពិភពលោកប្រឆាំងនឹងអំពើទារុណកម្ម (OMCT) បណ្តាញប្រឆាំងអំពើទារុណកម្ម អែស អូ អែស សមាជិកនៃដៃគូសន្ធនាអន្តរជាតិដើម្បីសេរីភាពបញ្ចេញមតិ (អាយហ្វិក) ដែលជាបណ្តាញសកលនៃសេរីភាពខាងបញ្ចេញមតិ និងសម្ព័ន្ធសារព័ត៌មានអាស៊ីអាគ្នេយ៍ (SEAPA) និងជាសមាជិកនៃសម្ព័ន្ធពិភពលោកដើម្បីការចូលរួមរបស់ប្រជាពលរដ្ឋ (“CIVICUS”) ផងដែរ។

គេហទំព័រអំពីសិទ្ធិមនុស្សកម្ពុជា www.sithi.org ជាជ័យលាភីដែលបានទទួលពានរង្វាន់មូលនិធិនៃការបង្កើតសង្គមសារព័ត៌មានថ្មីប្រចាំឆ្នាំ២០១១ស្ថិតក្នុងប្រភេទ “*សិទ្ធិនិងសេរីភាព*” និងបានទទួលពានរង្វាន់ទំនាក់ទំនងដើម្បីផ្លាស់ប្តូរសង្គមមកពីមជ្ឈមណ្ឌលសម្រាប់ទំនាក់ទំនងនិងការផ្លាស់ប្តូរសង្គមនៅសាកលវិទ្យាល័យឃ្វីនស្លែន ក្នុងទីក្រុងប្រ៊ីសបេន ប្រទេសអូស្ត្រាលី។